# អំពីរចនាសម្ព័ន្ធនៃសំណង់ព្រះវិហារក្នុងតំបន់អង្គរ

នៅក្នុងអត្ថបទរបស់លោក Henri Marchal ដែលមានចំណងជើងថា *Monuments secondaires et Terrasses bouddhiques d'Angkor-Thom*[1] នៅឆ្នាំ ១៩១៨ លោកបានសិក្សាអំពីសំណង់ព្រះពុទ្ធសាសនាថេរវាទមួយនៅក្នុងតំបន់អង្គរ ដែលហៅជាភាសាបារាំងថា "Terrasse bouddhique" គឺសំដៅលើព្រះវិហារ ឬឧបោសថាគារបច្ចុប្បន្ន។ បន្តបន្ទាប់មកមានអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិចាប់សិក្សាស្រាវជ្រាវលើប្រធានបទនេះកាន់តែធំទូលាយ។ ដោយឡែក ដោយសារតែនេះជាអត្ថបទខ្លីពុំអាចបង្ហាញប្រវត្តិ ស្រាវជ្រាវបានទាំងស្រុងទេ ប៉ុន្តែចំណងជើងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺរក្សាតាមឯកសារយោង។

ពាក្យព្រះវិហារឃើញមានដំបូងនៅក្នុងសិលាចារឹក កោរុង (K.505) ចុះកាលបរិច្ឆេទឆ្នាំ៦៣៩នៃគ.ស. ស្ថិតក្នុងខេត្តច័ន្ទបុរី បច្ចុប្បន្នក្នុងប្រទេសថៃ និងសិលាចារឹកគោកស្វាយចេក (K .754) បានបង្ហាញអំពីព្រះមហាក្សត្រស្រីន្ទ្រវរ្ម័នបានត្រាស់បង្គាប់ទៅឧបាសកម្នាក់ឈ្មោះ សិរិមាលិរតនលក្ខី ឲ្យកសាងព្រះវិហារមួយ ។ ចំពោះកាលបរិច្ឆេទនៃសិលាចារឹកនេះ គឺនៅសតវត្សទី១៤[2]នៃគ.ស។ នេះជាភស្តុតាងដ៏សំខាន់មួយសម្រាប់បង្ហាញពីវត្តមាននៃព្រះវិហារនាសម័យកណ្តាល។ ភស្តុតាងដំបូងនៃព្រះវិហារ ឬឧបោសថាគារឃើញមាននៅក្នុងប្រទេសកម្ពុជាប្រហែលក្នុងសតវត្សទី៨-៩[3]នៃគ.ស។ ភស្តុតាងដំបូងៗមាននៅលើភ្នំគូលែន រួមមាន សីមាពាមគ្រែ(ក្បែរបន្ទាយ) នឹងសីមាដូនមាស។ គួរឲ្យចាប់អារម្មណ៍ គឺនៅលើសន្លឹកសីមាទាំងនោះ មានឆ្លាក់រូបធម្មចក្រ រូបទម្រង់ចេតិយ និងរូបក្អមទឹក ដែលក្នុងសិល្បៈខ្មែរសម័យនោះកម្រឃើញបង្ហាញ។ គេគិតថា ទាំងនោះជាសិល្បៈមន នៃទ្វារបតី ដែលមាននៅក្នុងប្រទេសកម្ពុជានាសម័យនោះ ។

---

[1] Henri Marchal, 1918

[2] ដែលអ្នកស្រាវជ្រាវកំណត់ថាជាសិលាចារឹកភាសាបាលីចាស់ជាងគេក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន។ សូមអាន អាំង ជូលាន, សិលាចារឹកភាសាបាលីដែលចាស់ជាងគេនៅកម្ពុជា ។

[3] Tun Puthpiseth, 2015, p.59.

អត្ថបទដោយ៖ អេង តុលា

ចាប់ពីសតវត្សទី១៤មក ការកសាងសំណង់ប្រាសាទស្ទើមស្ទៃលែងមានទៀត ហើយ ប៉ុន្តែជំនួសមកវិញនូវសំណង់ព្រះវិហារ ឬឧបោសថាគារ និងចេតិយ ហើយគេយកថ្មប្រាសាទមកធ្វើ។ យើងបានដឹងហើយថា អាគារចម្បងសម្រាប់ព្រះពុទ្ធសាសនា គឺព្រះវិហារ ឬឧបោសថាគារនេះឯង ដែលជាកន្លែងសក្ការៈសម្រាប់ព្រះសង្ឃបំពេញធម៌ ឬធ្វើឧបោសថសីលជាដើម ។

សំណង់ព្រះវិហារនៅក្នុងតំបន់អង្គរ និងក្រៅតំបន់អង្គរមានយ៉ាងសន្ធឹកសន្ធាប់ទាំងនៅទីវាល និងនៅក្នុងព្រៃ ហើយមានរចនាសម្ព័ន្ធខុសគ្នា។ តាមរបាយការណ៍របស់អាជ្ញាធរជាតិអប្សរា សំណង់ព្រះវិហារក្នុងក្រុងអង្គរមានប្រមាណជាង៨០ ដោយបែងចែកជា៤ជ្រុង (ទ្វារក្រុង) ជ្រុងលិច កើត ជើង និងត្បូង ដែលកំណត់យកប្រាសាទបាយ័នជាគោល។

រចនាសសម្ព័ន្ធនៃសំណង់ព្រះវិហារ ពុំមានទ្រង់ទ្រាយដូចគ្នាទាំងស្រុងនោះទេ តែគេអាចកំណត់ទ្រង់ទ្រាយគោលចំនួន៣ ដូចខាងក្រោម ៖

- មានខឿនរាងចតុកោណវែង ដែលកសាងអំពីថ្មបាយក្រៀមឬថ្មភក់។ សសរឈើគ្មានជញ្ជាំង និងប្រក់ក្បឿង។ ភាគច្រើនបែរទៅទិសខាងកើត។ ជួនកាលកសាងជាខឿនចតុកោណវែង ខាងក្រោយមានចេតិយ និងជួនកាលទៀតកសាងជាខឿនចតុកោណវែងទោល ពុំមានជាប់នឹងប្រាសាទ ឬចេតិយនោះទេ ។
- មានសន្ធឹកសីមាទោល ឬគ្រោះនៅតាមទិសទាំង៨។ ខ្លះទៀតមានកូនចេតិយនៅជុំវិញនៃព្រះវិហារ។ សីមានៅខាងមុខព្រះវិហារ ហៅថាសីមាឥន្ទ្រកិល ។
- នៅចុងខាងលិចនៃខឿនព្រះវិហារមានតម្កល់ព្រះដី[4]។

សំណង់នេះមានចំនួនបីប្រភេទ គឺ ព្រះវិហារទោល ,ព្រះវិហារជាប់ ឬមុខប្រាសាទ និង ព្រះវិហារចេតិយជុំវិញ ឬខាងក្រោយមានចេតិយ។ រីឯវត្ថុដែលកំណត់ថាទីកន្លែងនេះ

[4] ព្រះពុទ្ធរូបអង្គធំតម្កល់លើបល្ល័ង្កក្នុងព្រះវិហារ ឬឧបោសថាគារ ។

ជាទីសក្ការៈគឺ សន្ទឹកសីមាដែលព័ទ្ធជុំវិញទិសធំទាំង៤ និងអនុទិស៤ ករណីដូចនៅសីមានៅលើភ្នំគូលែន មានតែសន្ទឹកសីមាជុំវិញ ពុំមានខឿនថ្មភក់ ឬបាយក្រៀមនោះទេ ។

សង្កេតឃើញថាសំណង់ព្រះវិហារក្នុងតំបន់អង្គរមានប្រមាណជាង៨០ ប៉ុន្តែមានរូបរាងរចនាសម្ព័ន្ធជាក់លាក់តែ១២ប៉ុណ្ណោះ។ សំណង់ផ្សេងៗទៀតស្ថិតនៅក្នុងព្រៃអង្គរ និងកប់ក្នុងដី[5]។ សំណង់ព្រះវិហារទៅ១២នេះ ស្ថិតនៅជុំវិញប្រាសាទបាយ័ន ដែលមានដូចជានៅប្រាសាទតុបខាងលិច, ប្រាសាទតាទូត, ប្រាសាទព្រះខ័ន, ប្រាសាទបន្ទាយក្ដី, ព្រះវិហារទេពប្រណម្យ, ព្រះវិហារព្រះសេអារ្យ, ព្រះវិហារប្រាំពីរល្វែង, ព្រះវិហារប្រាំបួនល្វែង, ព្រះវិហារព្រះអង្គគោកធ្លក, ព្រះវិហារព្រះឥន្ទ្រទេព, ព្រះវិហារព្រះអង្គខ្មៅ, ព្រះវិហារព្រះអង្គផោក និងនៅក្រៅតំបន់អង្គរ មានដូចជា នៅប្រាសាទវត្តចេតិយ, ប្រាសាទព្រះធាតុខ្វាវ, ប្រាសាទនគរបាជ័យ ប្រាសាទចៅស្រីវិបុលជាដើម ។

សំណង់ព្រះវិហារនៅក្នុងតំបន់អង្គរ ប្រហែលជាកសាងចាប់ពីសតវត្សទី១៣ ដល់ ១៨នៃគ.ស.[6]។ ករណីសិលាចារឹកភូមានៅលើសន្ទឹកសីមា នៅព្រះវិហារព្រះអង្គផោក ប្រហែលជាធ្លាក់នៅក្រោយស.វ.ទី១៨[7] ។

---

[5] អេង តុលា, 2019, p.88

[6] Tun Puthpiseth, 2015, p.63.

[7]SPAFA, Myanmar inscriptions found at Angkor, 2013, p. 15.

អត្ថបទដោយ៖ អេង តុលា




រូបលេខ២១៖ ប្លង់ទូទៅនៃសីមាពាមគ្រែ
ប្រភព៖ កែសម្រួលពី J.Boulbet & B. Dagens




រូបលេខ២២៖ ប្លង់ទូទៅនៃសីមាដូនមាស
ប្រភព៖ កែសម្រួលពី Boulbet J& B. Dagens



រូបលេខ២៣៖ សន្ទឹកសីមានៃសីមាពាមគ្រែ និងដូនមាស

អត្ថបទដោយ៖ អេង តុលា




អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥៖ គំនូរឡើងវិញ និងរូបទូទៅនៃព្រះវិហារប្រាសាទតាទូត
(ក្នុងក្រុមប្រាសាទព្រះពិធូ) ព្រះវិហារខាងមុខប្រាសាទ



រូបលេខ២៦៖ គំនូរឡើងវិញ និងរូបទូទៅនៃព្រះវិហារព្រះអង្គជោក
( ព្រះវិហារមានចេតិយខាងក្រោយ )

អត្ថបទដោយ៖ អេង តុលា









អត្ថបទដោយ៖ អេង តុលា





រូបលេខ១០៖ ថតចំហៀងនៃព្រះវិហារព្រះឥន្ទ្រទេព ( ព្រះវិហារចេតិយខាងក្រោយ )

អត្ថបទដោយ៖ អេង តុលា





អត្ថបទដោយ៖ អេង តុលា







អត្ថបទដោយ៖ អេង តុលា



អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង


**អាំង ជូនលាន**

២០០៨ សិលាចារឹកភាសាបារីចាស់ជាងគេនៅកម្ពុជា, ឧទ័យលេខ៩,ភ្នំពេញ

**ព្រាប ចាន់ម៉ារ៉ា**

២០១៧ ទម្រង់ប្រពៃណីខ្មែរ សំណង់តាមវត្ត , ភ្នំពេញ

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសហការជាមួយសាកលវិទ្យាល័យតូរិនតូ កាណាដា**

២០១៩ គម្រោង Angkor Vihara, សៀមរាប

**ញឹម សុធារិទ្ធ**

២០១៩ ការធ្វើកំណាយនៅប្រាសាទបន្ទាយក្តី, សៀមរាប

**អេង តុលា**

២០១៩ ពិចារណាអំពីរចនាសម្ព័ន្ធនៃសំណង់ឧបោសថាគារសម័យកណ្តាល, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី២៧នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

## ឯកសារបរទេស

**Henri Marchal**

1918 Monuments secondaires et terrasses bouddhique d’Angkor Thom , BEFEO

**A.Thompson**

1999 Mémoire du Cambodge

2004 A pilgrins to angkor a buddhist cosmopolis in South Asia


អត្ថបទដោយ៖ អេង តុលា

**Tun Puthpiseth**

2015 Bouddhisme theravada et production artisitque en pays khmer : Étude d'un corpus d'images en ronde-bosse du Buddha (XIIIe -XVIe siécles)

**SPAFA**

2013 Myanmar inscriptions found at Angkor

**EA, Darith**

2018 Evidence of theravada buddhist structures in Angkor form 13th to 18th centuries , APSARA Authority

**Andrew Harris**

2019 An Old Ritual Capital, a New Ritual Landscape: Understanding the Transformation

of Angkor Thom, Cambodia through the Construction and Placement of Theravāda »Buddhist Terraces«, PhD Candidate, University of Toronto

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION